ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៣

ក្រសួងសុខាភិបាល

លេខ:..០០...7.....អបស/មព

# ប្រកាស

## ស្តីពី

## ការផ្តល់ផ្លាកសញ្ញាសំគាល់ (Logo) ថ្មី ដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

※※※

## ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១៩៩៨ ចុះថ្ងៃទី ៣០-១១-១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤-០១-១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ-កត ចុះថ្ងៃទី២២-១០-៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈ ឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

-យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សំរេច

**ប្រការ១** : ដើម្បីពង្រឹងការអនុវត្តន៍បទដ្ឋានបច្ចេកទេសនៅតាម សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន និងដើម្បីលើកទឹកចិត្តដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនណា ដែលបានអនុវត្តជាប្រចាំ តាមការណែនាំរបស់ក្រសួងសុខាភិបាល នោះ ក្រសួងសុខាភិបាលនឹងផ្តល់ជូននូវ ផ្លាកសញ្ញាសំគាល់ (Logo) ថ្មីដល់ សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រឯកជនទាំងនោះ ។

**ប្រការ២** : ផ្លាកសញ្ញាសំគាល់ (Logo) ថ្មីសំរាប់ មន្ទីរពហុព្យាបាល មន្ទីរសំរាកព្យាបាលឯកទេស មន្ទីរសម្ភព មានលក្ខណៈដូចខាងក្រោមនេះ:

-ជាបន្ទះប្លាស្ទិកទំហំ ៦០សម x ៤០សម ព័ទ្ធជុំវិញដោយសរសៃរឆ្នូតពណ៌ខៀវទឹកប៊ិច ទទឹង ០,៨ សម

-បន្ទះប្លាស្ទិកនេះចែកចេញជាពីរផ្នែក:

ក- ផ្នែកខាងលើពណ៌លឿងទុំ ទំហំ ៤០សម x ១៦ សម មានសរសេរអក្សរពណ៌ខៀវទឹកប៊ិចថាស: លិខិតអនុញ្ញាត របស់ក្រសួងសុខាភិបាល (កំពស់ ៣ សម) ៦៤

លេខ:............អបស-មព   ចុះថ្ងៃទី.................. (កំពស់ ២ សម )

ខ- ផ្នែកខាងក្រោមពណ៌ស  ទំហំ ៤៤ សម x ៤០ សម  មានសញ្ញាកាកបាទ ផ្ទៃសនៅចំកណ្តាល ដែលជ្រុងនិមួយៗ ប្រវែង ១០សម ព័ទ្ធជុំវិញដោយសរសៃ ឆ្នូតពណ៌ខៀវទឹកប៊ិចចាស់   ទទឹង ០.៥ សម

-នៅចំកណ្តាលសញ្ញាកាកបាទមាន ដំបងថ្លោងមួយរុំព័ទ្ធដោយពស់មួយពណ៌ខៀវទឹកប៊ិចចាស់ដូចគ្នា ។ ដំបងថ្លោងមានកំពស់  ២៦ សម   និងក្បាលថ្លោងមានប្រវែង   ៣ សម ។

**ប្រការ៣** : ផ្លាកសញ្ញាសំគាល់ (Logo)   ថ្មីសំរាប់បន្ទប់ពិគ្រោះព្យាបាលជំងឺ បន្ទប់ពិគ្រោះព្យាបាលជំងឺវេទនសាស្ត្រ ( មាត់-ធ្មេញ) បន្ទប់ពិគ្រោះព្យាបាលដោយចលនា បន្ទប់ថែទាំជំងឺ បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់សោភ័ណសល្យសាស្ត្រ មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មានលក្ខណៈដូចខាងក្រោមនេះ:

-ជាបន្ទះប្លាស្ទិកទំហំ   ៤៥ សម x ៣៥ សម ព័ទ្ធជុំវិញដោយសរសៃរឆ្នូតពណ៌ខៀវទឹកប៊ិចចាស់  ទទឹង ០.៨ សម

-បន្ទះប្លាស្ទិកនេះចែកចេញជាពីរផ្នែក:

ក- ផ្នែកខាងលើពណ៌លឿងទុំ ទំហំ   ៣៥សម x ១១ សម មានសរសេរអក្សរពណ៌ខៀវទឹកប៊ិចចាស់: លិខិតអនុញ្ញាតរបស់ក្រសួងសុខាភិបាល    (កំពស់  ២.៥ សម )

លេខ:.............អបស-មព   ចុះថ្ងៃទី..................... (កំពស់ ១.៥ សម )

ខ- ផ្នែកខាងក្រោមពណ៌ស ទំហំ ៣៥ សម x ៣៤ សម  មានសញ្ញាកាកបាទ ផ្ទៃសនៅចំកណ្តាល ដែលជ្រុងនិមួយៗ  ប្រវែង ៩ សម ព័ទ្ធជុំវិញដោយសរសៃរឆ្នូតពណ៌ខៀវទឹកប៊ិចចាស់ ទទឹង ០.៥ សម

-នៅចំកណ្តាលសញ្ញាកាកបាទមាន ដំបងថ្លោងមួយរុំព័ទ្ធដោយពស់មួយពណ៌ខៀវទឹកប៊ិចចាស់ដូចគ្នា ។ ដំបងថ្លោងមានកំពស់  ២៣ សម   និងក្បាលថ្លោងមានប្រវែង   ២ សម ។

**ប្រការ៤** : សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ទាំងឡាយណា ដែលបានទទួលផ្លាកសញ្ញាសំគាល់ថ្មី ពីក្រសួងសុខាភិបាលហើយ ត្រូវខិតខំពង្រឹងការអនុវត្តន៍ បទដ្ឋាននានា ឱ្យមានដំណើរការល្អជាប្រចាំ  និងអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល ។ ក្នុងករណីមិនអនុវត្តតាម ការណែនាំរបស់ក្រសួងសុខាភិបាល ក្រសួងមានសិទ្ធិដកហូតផ្លាកសញ្ញាសំគាល់ថ្មីដោយស្វ័យប្រវត្តិ ។

**ប្រការ៥** : ជនណាក្លែងបន្លំ ឬមានចេតនាក្លែងបន្លំ ផ្លាកសញ្ញាសំគាល់ថ្មីរបស់ក្រសួងសុខាភិបាល ដែលមានលក្ខណៈដូចបានជំរាបជូនក្នុង  ប្រការ២និង៣ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ៦** : អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងសុខាភិបាល  អគ្គាធិការដ្ឋានក្រសួងសុខាភិបាល នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល មន្ទីរសុខាភិបាលរាជធានីនិងខេត្តក្រុង



ក្រសួងសុខាភិបាល លេខ: ១៥១-១៥៣ ផ្លូវ កម្ពុជាក្រោម ភ្នំពេញ - ទូរស័ព្ទទូរសារ (៨៥៥ ២៣) ៤២៦៨៤១ - ៧២២៩៣៣ - ៣៦៦៨៥០
TRY OF HEALTH; NO. 151-153 AVENUE KAMPUCHEA KROM, PHNOM PENH, CAMBODIA. FAX/PHONE (855-23) 426841, 722933 E-mail: MOH@camnet.com.kh

សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**<u>ប្រការ៧</u>** : ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២3 ខែ 03 ឆ្នាំ២០០៩

**<u>ចំលងជូន:</u>**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងយុត្តិធម៌

-ក្រសួងមហាផ្ទៃ

-ក្រសួងទំនាក់ទំនងសភានិងអធិការកិច្ច

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ក្រសួងពាណិជ្ជកម្ម

-សាលាក្រុងភ្នំពេញនិងខេត្តក្រុង

"ដើម្បីជ្រាបជាពត៌មាន"

-ដូចប្រការ៦

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

វេជ្ជ.ហួន_ស៊ុនហួត



ទីស្តីការក្រសួងសុខាភិបាល លេខ: ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ - ទូរស័ព្ទទូរសារ (៨៥៥ ២៣) ៤២៦៨៤១ - ៧២២៩៣៣ - ៣៦៦៩៥០
MINISTRY OF HEALTH: NO. 151-153 AVENUE KAMPUCHEA KROM, PHNOM PENH, CAMBODIA. FAX PHONE (855-23) 426841, 722933 E-mail: MOH@camnet.com.kh